ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ២១ លេខ ៣ ខែកញ្ញា ២០១៧ តម្លៃ ១.៥០០៛

# វិធានការមិនមែនពន្ធគយនៅកម្ពុជា



រយៈពេលសម្រាប់ការលុបបំបាត់ របាំងមិនមែនពន្ធគយ ប្រែប្រួលខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ។
ខេត្តព្រះសីហនុ ខែកុម្ភៈ ឆ្នាំ២០១៧

## សេចក្តីផ្តើម

អ្នកសិក្សាស្រាវជ្រាវ អ្នកកសាងគោលនយោបាយ និងអ្នកអនុវត្តជាក់ស្តែង ដែលកំពុងធ្វើការក្នុងវិស័យពាណិជ្ជកម្ម បានយកចិត្តទុកដាក់ជាខ្លាំងលើវិធានការមិនមែនពន្ធគយ (NTMs) ព្រោះ នៅពេលមានការកាត់បន្ថយពន្ធគយ តាមរយៈ កិច្ចព្រមព្រៀងពាណិជ្ជកម្មកម្រិតតំបន់ កិច្ចព្រមព្រៀងពហុភាគី និងទ្វេភាគីនោះ ការប្រើវិធានការមិនមែនពន្ធគយ (NTMs) ដើម្បីគ្រប់គ្រងពាណិជ្ជកម្ម ក៏បានកើនឡើងតាមការអះអាងថា គឺដើម្បីឆ្លើយតបទៅនឹងតម្រូវការការពារអ្នកប្រើប្រាស់ និងបរិស្ថានឲ្យបានកាន់តែប្រសើរ។ ប៉ុន្តែ NTMs ក៏ត្រូវបានប្រើប្រាស់សម្រាប់ជំនួសពន្ធគយដែរ ដើម្បីការពារ ឧស្សាហកម្ម ទីផ្សារ និងផលិតផលក្នុងស្រុក។ ម្យ៉ាងទៀត ការអនុវត្តតាម NTMs វាបង្កើនចំណាយលើការនាំចេញ ហើយនៅទីបំផុតអាចនាំឲ្យថយចុះលំហូរពាណិជ្ជកម្ម។ ចំណាយធ្វើពាណិជ្ជកម្មទៅលើពន្ធគយ មានត្រឹមតែ ២ ទៅ ៣% នៃចំណាយធ្វើពាណិជ្ជកម្មសរុបប៉ុណ្ណោះ ក្នុងបណ្តាប្រទេសអាស៊ីប៉ាស៊ីហ្វិកនានា ចំណែកឯចំណាយធ្វើពាណិជ្ជកម្ម ដែលជាប់ទាក់ទិននឹងគោលនយោបាយ និងវិធានការមិនមែនពន្ធគយ មានរហូតដល់ ៧៦ ទៅ ៧៨% (Duval, Saggu and Utokham 2015 10-11)។ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ NTMs មានផលពាក់ព័ន្ធច្រើនសម្រាប់លទ្ធភាពចូលទីផ្សារ ព្រោះការអនុវត្តតាម NTMs ទាមទារសមត្ថភាពបច្ចេកទេសច្រើន និងសម្ភារឧបទេសតាមស្តង់ដាអន្តរជាតិ ដែលជារឿយៗប្រទេសទាំងនេះពុំទាន់មានទេ ហើយចំណាយខ្ពស់អាចនាំឲ្យចាញ់ប្រៀបគេក្នុងការប្រកួតប្រជែង។ ប៉ុន្តែទាំងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍ សព្វថ្ងៃកំពុងបង្កើនការដាក់អនុវត្ត NTMs របស់ខ្លួន។

ប្រទេសនានាតែងដាក់អនុវត្ត NTMs លើផលិតផលជាក់លាក់ ដើម្បីការពារជីវិតមនុស្ស សត្វ និងរុក្ខជាតិ ហើយនិងបរិស្ថាន។ វិធានការទាំងនេះជាអត្ថបទច្បាប់ស្មុគស្មាញ និងមានច្រើនមុខច្រើនបែបណាស់ ដូច្នេះតែងចោទបញ្ហាដល់ការធ្វើចំណាត់ថ្នាក់ និងការកំណត់និយមន័យ។ សន្និសីទអង្គការសហប្រជាជាតិលើពាណិជ្ជកម្មនិងការអភិវឌ្ឍ (UNCTAD) បានធ្វើចំណាត់ថ្នាក់ NTMs ដោយចែកចេញជា ១៦ប្រភេទមានលេខកូតពី A ដល់ P (តារាង១)។ ទោះបីកន្លងមកមានសំណើជាច្រើនដែលព្យាយាមផ្តល់និយមន័យសាមញ្ញៗដល់ NTMs ក្តី ក៏មិនទាន់មានមួយណាដែលមានន័យសព្វគ្រប់ល្អនោះទេ។ ហើយទោះបីមិនទាន់មាននិយមន័យមួយណាដែលគេបានឯកភាពគ្នាក៏ដោយ ក៏អង្គការពាណិជ្ជកម្មពិភពលោក (WTO 2012, 72) បានពិពណ៌នាពី NTMs យ៉ាងទូលាយថាជា:

---

អត្ថបទនេះ រៀបរាងដោយលោក វ៉ែន សីហា ជាអ្នកស្រាវជ្រាវ ផ្នែកសេដ្ឋកិច្ច នៅវិទ្យាស្ថាន CDRI។ សូមយោងឯកសារនេះថា៖ Ven Seyhah. 2017. “Existing Non-Tariff Measures in Cambodia.” *Cambodia Development Review* 21 (3): 1-6. ភ្នំពេញ៖ វិទ្យាស្ថាន CDRI។

## មាតិកា

វិធានការមិនមែនពន្ធគយនៅកម្ពុជា.................................... ១
តើកត្តាអ្វីជំរុញឲ្យអាជ្ញាធរមូលដ្ឋានមានការឆ្លើយតប? បទពិសោធន៍ទទួលបានពីគម្រោងពីរទាក់ទងនឹងគណនេយ្យភាពសង្គមនៅកម្ពុជា .................................. ៧
តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស ....................... ១១
– ស្ថានភាពក្នុងប្រទេស........................ ១៣
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ......................................... ២០

...វិធានការផ្នែកគោលនយោបាយ ក្រៅពីពន្ធគយធម្មតា ដែលប៉ះពាល់ដល់ពាណិជ្ជកម្មអន្តរជាតិនៃ ទំនិញនៅតាមព្រំដែន ដោយធ្វើឲ្យមានការប្រែប្រួលបរិមាណជួញដូរ ថ្លៃទំនិញ ឬក៏ទាំងពីរមុខ។ NTMs រួមមាន វិធានការជាច្រើន ដូចជា កូតា, អាជ្ញាប័ណ្ណ, របាំងបច្ចេកទេសលើពាណិជ្ជកម្ម (TBTs), វិធានការផ្នែកអនាម័យ និងភូតគាមអនាម័យ (SPS), ការរឹតបន្តឹងលើការនាំចេញ, ការយកកម្រៃគយបន្ថែម, វិធានការហិរញ្ញវត្ថុ, និង វិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃ ជាដើម។

អត្ថបទនេះមានគោលដៅផ្តល់ការបូកសរុបត្រួសៗពី NTMs មានស្រាប់ ដែលកម្ពុជាបានដាក់អនុវត្តលើផលិតផលនាំចូល និងផលិតផលនាំចេញ ដើម្បីឲ្យក្រុមហ៊ុនពាណិជ្ជកម្មនានាអាចយល់ដឹងបានកាន់តែច្បាស់ពីទំហំរបស់វា។ អត្ថបទក៏មានគោលដៅផ្តល់ជាចំណេះដឹងអនុវត្តជាក់ស្តែង សម្រាប់ការស្រាវជ្រាវបន្ថែមពី NTMs នៅកម្ពុជាដែរ។ ការពិនិត្យឡើងវិញយ៉ាងខ្លីលើឯកសារមានស្រាប់នៃការស្រាវជ្រាវជាក់ស្តែង បានអនុញ្ញាតឲ្យធ្វើសំយោគនូវលទ្ធផលរកឃើញថ្មីៗ។ បន្ទាប់មកមានការរៀបរាប់សង្ខេបពីការវិវត្ត NTMs និងបញ្ជី NTMs មានស្រាប់នៅកម្ពុជា ដែលបានធ្វើចំណាត់ថ្នាក់ទៅតាមប្រព័ន្ធសុខដុមនីយកម្ម (HS)។ បន្ទាប់មកទៀត មានការគណនាអត្រាគ្របដណ្តប់នៃ NTMs (NTM coverage ratio) សម្រាប់ការនាំចូលរបស់កម្ពុជា និងគម្លាតនៃបទបញ្ញត្តិច្បាប់ (regulatory distance) ស្តីពី NTMs នៅក្នុងអាស៊ាន។

## វិធីសាស្រ្តវិភាគ

ទិន្នន័យ NTMs បានប្រមូលយកពី ប្រព័ន្ធព័ត៌មានវិភាគពាណិជ្ជកម្ម (TRAINS) របស់ UNCTAD, មូលដ្ឋានទិន្នន័យរបស់ធនាគារពិភពលោកស្តីពី ដំណោះស្រាយពាណិជ្ជកម្មដាក់បញ្ចូលគ្នាក្នុងពិភពលោក (WITS), និងទិន្នន័យពាណិជ្ជកម្មបានពីមូលដ្ឋានទិន្នន័យ UN Comtrade ។ ដើម្បីកំណត់របាយ NTMs និងវាយតម្លៃពីឥទ្ធិពលជាក់ស្តែង ការសិក្សានេះបានគណនានូវវត្តមាន NTMs, អត្រាគ្របដណ្តប់នៃ NTMs និង គម្លាតបទបញ្ញត្តិ NTMs។

វត្តមាន NTMs (NTM incidence) "បង្ហាញតែ វត្តមាន ឬ អវត្តមាន នៃ NTMs និងបូកសរុប ភាគរយនៃផលិតផលដែលមានការអនុវត្ត NTMs មួយ ឬច្រើន" (UNCTAD 2013, 4)។

អត្រាគ្របដណ្តប់នៃ NTMs គឺជា ភាគរយនៃពាណិជ្ជកម្មដែលទទួលរង NTMs សម្រាប់ប្រទេសនាំចូល ហើយវាជារង្វាស់មួយសម្រាប់វាស់វែង ឥទ្ធិពល នៃ NTMs លើការនាំចូលជាទូទៅ (UNCTAD 2013, 4)។

ដោយមាន Cadot et al. (2015) បានណែនាំឲ្យប្រើនោះ គម្លាតបទបញ្ញត្តិ វាជា ភាពខុសគ្នា ឬ ភាពស្រដៀងគ្នារវាងរបប NTMs ផ្សេងៗ នៃប្រទេសខុសៗគ្នា។ គម្លាតបទបញ្ញត្តិ អាចគណនាដូចតទៅ។ ទី១ ប្រសិនបើប្រទេសពីរអនុវត្ត NTMl លើផលិតផល K ដែលមានលេខ HS ៦ខ្ទង់, ដូច្នេះ គម្លាតបទបញ្ញត្តិក្នុង NTM1 លើផលិតផល K នៃប្រទេសទាំងពីរ គឺ RDlk =0; RDlk=1។ តាមនេះ ដោយប្រើរូបមន្ត

$$Dij = \frac{sum\ of\ RD_{lk}\quad sum\ of\ RD_{lk}}{count\ of\ RD_{lk}\, count\ of\ RD_{lk}}$$

តារាង១៖ NTMs តាមចំណាត់ថ្នាក់ UNCTAD

| | | លេខកូត | ពិពណ៌នា |
|---|---|---|---|
| វិធានការពាក់ព័ន្ធនឹងការនាំចូល | វិធានការបច្ចេកទេស | A | វិធានការអនាម័យ និងភូតគាមអនាម័យ |
| | | B | របាំងបច្ចេកទេសលើពាណិជ្ជកម្ម |
| | | C | អធិការកិច្ចមុនពេលដឹកជញ្ជូន និងបែបបទផ្សេងៗ |
| | វិធានការមិនមែនបច្ចេកទេស | D | វិធានការត្រៀមសម្រាប់ការពារពាណិជ្ជកម្ម, |
| | | E | កូតា, ការផ្តល់អាជ្ញាប័ណ្ណមិនស្វ័យប្រវត្តិ, ការហាមឃាត់, និង វិធានការគ្រប់គ្រងបរិមាណ |
| | | F | វិធានការគ្រប់គ្រងថ្លៃ រួមទាំង ការយកពន្ធ និងយកកម្រៃបន្ថែម |
| | | G | វិធានការហិរញ្ញវត្ថុ |
| | | H | វិធានការប៉ះពាល់ដល់ការប្រកួតប្រជែង |
| | | I | វិធានការវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម |
| | | J | ការដាក់កម្រិតលើការចែកចាយ |
| | | K | ការដាក់កម្រិតលើសេវាក្រោយពេលលក់ |
| | | L | ឧបត្ថម្ភធន (ក្រៅពីឧបត្ថម្ភធនលើការនាំចេញ) |
| | | M | ការដាក់កម្រិតលើលទ្ធកម្មរបស់រដ្ឋាភិបាល |
| | | N | កម្មសិទ្ធិបញ្ញា |
| | | O | ច្បាប់ស្តីពីប្រភពដើម |
| | | P | វិធានការទាក់ទងនឹងការនាំចេញ |

ប្រភព: UNCTAD (2015)

គេអាចគណនាគម្លាតបទបញ្ញត្តិសរុប Dij រវាងប្រទេសកំពុងសិក្សា ហើយបំលែង តម្លៃ Dij ទាំងអស់ ទៅជា ម៉ាទ្រីសមិនស៊ីម៉េទ្រី។ ការកែខ្នាតច្រើនមុខ( multidimentional scaling ) ត្រូវអនុវត្តឡើងដោយប្រើកម្មវិធីកុំព្យូទ័រ Stata ហើយតម្លៃគណនាឃើញអាចយកទៅដាក់លើគំនូរក្រាហ្វិក ដើម្បីបង្ហាញនូវភាពស្រដៀងគ្នានៃបទបញ្ញត្តិ NTMs ពីប្រទេសមួយទៅប្រទេសមួយដែលបានយកមកសិក្សា។

## ការសិក្សាមួយចំនួនក្នុងពេលកន្លងមកលើ NTMs និងពាណិជ្ជកម្ម

លទ្ធផលស្រាវជ្រាវឃើញជាក់ស្តែង លើឥទ្ធិពលផ្នែកពាណិជ្ជកម្មនៃ NTMs នៅកម្ពុជា នៅមានតិចនៅឡើយ ជាពិសេសការសិក្សាដែលប្រើឧបករណ៍វិភាគយ៉ាងម៉ត់ចត់។ ករណីសិក្សាប្រទេសមួយ អនុវត្តឡើងដោយ Dourng and Sok (2005) បានសន្និដ្ឋានថា NTMs ដែលក្រុមហ៊ុននាំចេញនៅកម្ពុជាត្រូវប្រឈមមុខ គឺជាប់ទាក់ទងភាគច្រើនទៅនឹងវិធានការអនាម័យនិងភូតគាមអនាម័យ (SPS) ហើយបន្ទាប់មកទៀត គឺឧបត្ថម្ភធនរបស់រដ្ឋាភិបាល, នីតិវិធីគយ និងរដ្ឋបាល, និងរបាំងបច្ចេកទេសលើពាណិជ្ជកម្ម(TBT) រីឯកង្វះចំណេះដឹងជំនាញផ្នែកបច្ចេកទេស និងកង្វះមន្ទីរពិសោធន៍ស្របតាមស្តង់ដាអន្តរជាតិ គឺជា ឧបសគ្គចម្បងៗជាប់ទាក់ទងនឹង NTMs ដែលរារាំងពាណិជ្ជកម្ម។ អ្នកនិពន្ធនៃការសិក្សានេះបានពិចារណាថា ប្រសិនបើលុប NTMs ចោល ការនាំចេញរបស់កម្ពុជាអាចរីកធំ និងកាន់តែចម្រុះបែប ហើយអាចជួយជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។

ការស្រាវជ្រាវដោយ មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (២០១៤) ពីទស្សនៃក្រុមហ៊ុននានាលើ NTMs បានរកឃើញថា ៦៩% នៃក្រុមហ៊ុនឆ្លើយសម្ភាសន៍នៅកម្ពុជា ត្រូវប្រឈមមុខនឹងរបាំងពាណិជ្ជកម្ម ។ ក្នុងចំណោមប្រទេសសមាជិកអាស៊ាន កម្ពុជាមានអត្រាខ្ពស់ជាងគេ (៨២%) នូវក្រុមហ៊ុនដែលត្រូវប៉ះពាល់ដោយ NTMs តឹងរឹងខ្លាំង។ ផលិតផលកសិ-ស្បៀងអាហាររងការប៉ះពាល់ខ្លាំងជាងគេ ដោយមានដល់ ៨៩% នៃអ្នកនាំចេញផលិតផលកសិកម្ម កំពុងប្រឈមនឹងការលំបាកស្មុគស្មាញ។ អ្នកនាំចេញគិតថា ការសុំវិញ្ញាបនប័ត្រប្រភពដើមលំបាកខ្លាំងជាងគេ ហើយបន្ទាប់មក គឺ ការបំពេញតាមការតម្រូវផ្សេងៗនៃការវាយតម្លៃពីភាពត្រឹមត្រូវតាមលក្ខខណ្ឌកំណត់។

ការធ្វើចំណាត់ថ្នាក់ NTMs នៅកម្ពុជា ដោយ Sotharith, Tobing and Widiana’s (2016) បានរកឃើញ ២៤៣ NTMs ដែលប៉ះពាល់ដល់ ៩.៥៥៨ផលិតផល (Harmonised System [HS]codes),ឬ១០០%នៃផលិតផលទាំងអស់ដែលមានការជួញដូរនៅកម្ពុជា។ ការធ្វើចំណាត់ថ្នាក់នេះផ្អែកលើ ៥២ បទបញ្ញត្តិ NTMs ដែលភាគច្រើនចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ វិធានការបច្ចេកទេស ជា NTMs មានដាក់អនុវត្តញឹកញាប់ជាងគេ ដោយតំណាងឲ្យ ៦៥,០% នៃចំនួនសរុប ក្នុងនោះវិធានការរបាំងបច្ចេកទេសលើពាណិជ្ជកម្ម (TBTs) មានដល់ ៤៩,៨% ហើយការតម្រូវឲ្យមាន ការអនុញ្ញាត សម្រាប់មូលហេតុទាក់ទងនឹងរបាំងបច្ចេកទេសលើពាណិជ្ជកម្ម(TBT) B14[1] គឺមាន

1 ការតម្រូវថា អ្នកនាំចូលគួរទទួលបានការអនុញ្ញាត ឬការយល់ព្រមពីស្ថាប័នរដ្ឋពាក់ព័ន្ធ នៃប្រទេសគោលដៅ សម្រាប់ហេតុផល ដូចជា សន្តិសុខជាតិ ការការពារបរិស្ថាន ។ល។ ឧទាហរណ៍៖ ត្រូវមានការអនុញ្ញាតសម្រាប់ការនាំចូលឱសថ សំណល់និងសំរាម កាំភ្លើង ...(UNCTAD 2015,16)

រូបភាព១៖ ចំនួន NTMs គិតតាមឆ្នាំ ពីឆ្នាំ១៩៩៨-២០១៣




ប្រភព: UNCTAD TRAINS-NTMs (http://asean.i-tip.org/)

សំគាល់: CTPM: វិធានការត្រៀមសម្រាប់ការពារពាណិជ្ជកម្ម, EXP: វិធានការលើការនាំចេញ, INSP: អធិការកិច្ចមុនពេលដឹកជញ្ជូន, QC: ការត្រួតពិនិត្យបរិមាណ PC: ការត្រួតពិនិត្យថ្លៃ, SPS: វិធានការអនាម័យនិងភូតគាមអនាម័យ, TBT: របាំងបច្ចេកទេសលើពាណិជ្ជកម្ម

រូបភាព២៖ របាយ NTMs មានស្រាប់គិតតាមប្រភេទ




ប្រភព: UNCTAD TRAINS-NTMs (http://asean.i-tip.org/)

ការដាក់អនុវត្តញឹកញាប់ជាងគេ។ វិធានការលើការនាំចេញ (EXP) មានដល់ ២៨,៨% នៃ NTMs ទាំងអស់ ហើយប៉ះពាល់ដល់ផលិតផលទាំងអស់ដែលត្រូវនាំចេញពីកម្ពុជា។ ផលិតផលត្រូវប៉ះពាល់ដោយ NTMs ចាប់ពី ៣ ឡើងទៅ គឺមាន ម៉ាស៊ីនផ្សេងៗ (២១,៦%) ផលិតផលគីមី(១២,១%) វាយនភ័ណ្ឌ(១១,៣%) និងលោហៈ(៩,៥%)។

ការសិក្សារបស់ Ven (2017) បានពិនិត្យពីឥទ្ធិពលនៃ NTMs របស់ដៃគូពាណិជ្ជកម្ម ទៅលើការនាំចេញផលិតផលកសិកម្មរបស់កម្ពុជា ហើយបានរកឃើញថា ផលិតផលកសិកម្មកម្ពុជាស្ទើរតែទាំងអស់ ត្រូវទទួលរង NTMs ។ វិធានការផ្នែកអនាម័យ និងភូតគាមអនាម័យ (SPS) និង របាំងបច្ចេកទេសលើពាណិជ្ជកម្ម (TBT) មានអត្រាគ្របបណ្តប់ខ្ពស់ជាង របាំងមិនមែនបច្ចេកទេស (NTBs) រីឯវិធានការ SPS គឺជា NTMs ភាគច្រើនដែលដាក់អនុវត្តដោយអ្នកនាំចូលចម្បងៗនូវ ផលិតផលកសិកម្មរបស់កម្ពុជា។ របប NTMs លើផលិតផលកសិកម្ម របស់កម្ពុជា ខុសប្លែកពីដៃគូនាំចេញសំខាន់ៗរបស់ខ្លួន ប៉ុន្តែស្រដៀងគ្នានឹងប្រទេសវៀតណាម និង សិង្ហបុរី។ អ្នកនិពន្ធបានសន្និដ្ឋានថា SPS និង TBT ទំនងជាមិនអាចរារាំងការនាំចេញផលិតផលកសិកម្មទេ ពីព្រោះផលិតផលកសិកម្មសំខាន់ៗរបស់កម្ពុជា សុទ្ធតែស្របតាមការតម្រូវផ្សេងៗផ្នែក SPS និង TBT ដែលអនុវត្តដោយដៃគូពាណិជ្ជកម្មដូចជា សហភាពអឺរ៉ុប សហរដ្ឋអាមេរិក ចិន ម៉ាឡេស៊ី ថៃ សិង្ហបុរី វៀតណាម ជាដើម ប៉ុន្តែក្រុមហុនពាណិជ្ជកម្មនៅកម្ពុជាអាចជួបប្រទះឧបសគ្គក្នុងដំណើរការ (procedure obstacles) អនុវត្តតាម NTMs ។ ទោះយ៉ាងនេះក្តី NTBs ទំនងរារាំងខ្លះដែរដល់ការ

តារាង២៖ វត្ថុមាន NTMs មានស្រាប់នៅកម្ពុជា

| ផ្នែក HS | TBT | SPS | INSP | CTPM | QC | PC | EXP | Total |
|---|---|---|---|---|---|---|---|---|
| **ចំនួនសរុបនៃ NTMs** | **121** | **36** | **1** | **0** | **3** | **12** | **70** | **243** |
| សត្វរស់ និងផលិតផលសត្វ | 12 | 19 | 0 | 0 | 1 | 5 | 28 | 65 |
| ផលិតផលបន្លែ | 29 | 19 | 0 | 0 | 1 | 7 | 40 | 96 |
| ខ្លាញ់សត្វនិងបន្លែ ប្រេង និង ក្រមួន | 11 | 18 | 0 | 0 | 1 | 3 | 27 | 60 |
| ម្ហូបអាហារបានរៀបចំ ភេសជ្ជៈ ទឹកក្រូច ទឹកខ្មេះ ថ្នាំជក់ | 30 | 34 | 0 | 0 | 1 | 6 | 35 | 106 |
| ឈើ, ស្មោរនិងផលិតផលធ្វើពីស្មោរ(ឧ. ឆ្នុកដប), គ្រឿងកន្ត្រកល្អី | 4 | 0 | 1 | 0 | 1 | 2 | 15 | 23 |
| ផលិតផលរ៉ែ | 17 | 0 | 0 | 0 | 2 | 1 | 14 | 34 |
| ផលិតផលគីមីនិងឧស្សាហកម្មជាប់ទាក់ទិន | 80 | 18 | 1 | 0 | 1 | 6 | 45 | 151 |
| ជ័រ, ប្លាស្ទិក និងផលិតផល, កៅស៊ូ និងផលិតផល | 16 | 1 | 0 | 0 | 1 | 1 | 13 | 32 |
| ស្បែក និងផលិតផល, គ្រឿងកែបសេះ, សម្ភារសម្រាប់ធ្វើដំណើរ | 5 | 11 | 1 | 0 | 2 | 3 | 19 | 41 |
| ក្រដាស, ផ្ទាំងក្រដាសក្រាស់ និងផលិតផល | 6 | 0 | 1 | 0 | 1 | 1 | 12 | 21 |
| វាយនភ័ណ្ឌ និងផលិតផល | 3 | 11 | 0 | 0 | 2 | 2 | 15 | 33 |
| ស្បែកជើង, មួក, ស្លាបសត្វ, ផ្កាសិប្បនិមិត្ត, ឆ្មិត | 4 | 11 | 1 | 0 | 2 | 4 | 19 | 41 |
| ផលិតផលធ្វើពី ថ្ម ម្នាងសិលា សេរ៉ាមិក កែវ | 2 | 0 | 0 | 0 | 1 | 1 | 8 | 12 |
| គុជ, ថ្ម និងលោហៈមានតម្លៃ, ប្រាក់កាក់ | 18 | 4 | 1 | 0 | 2 | 4 | 25 | 54 |
| អាវុធ និងគ្រាប់រំសេវ | 3 | 11 | 0 | 0 | 1 | 1 | 11 | 27 |
| លោហៈមូលដ្ឋាន និងផលិតផល | 8 | 0 | 1 | 0 | 1 | 1 | 11 | 22 |
| ម៉ាស៊ីន និងបរិក្ខារអគ្គិសនី | 22 | 0 | 0 | 0 | 1 | 1 | 7 | 31 |
| យានយន្ត យន្តហោះ និងនាវា | 6 | 0 | 0 | 0 | 2 | 0 | 7 | 15 |
| ឧបករណ៍, នាឡិកា, ប្រដាប់ថត និងប្រដាប់ចម្លង | 7 | 11 | 0 | 0 | 2 | 2 | 10 | 32 |
| ផលិតផលកម្មន្តសាលផ្សេងៗ | 15 | 11 | 1 | 0 | 2 | 3 | 24 | 56 |
| **ស្នាដៃសិល្បៈ និងវត្ថុបុរាណ** | **5** | **11** | **1** | **0** | **1** | **3** | **19** | **40** |
| **វត្ថុមាន NTMs** | **303** | **190** | **9** | **0** | **29** | **57** | **404** | **992** |

ប្រភព: UNCTAD TRAINS-NTMs (http://asean.i-tip.org/)

កំណត់សំគាល់៖ CTPM: វិធានការត្រៀមសម្រាប់ការពារពាណិជ្ជកម្ម, EXP: វិធានការលើការនាំចេញ, INSP: អធិការកិច្ចមុនពេលដឹកជញ្ជូន, QC: ការត្រួតពិនិត្យបរិមាណ, PC: ការត្រួតពិនិត្យថ្លៃ, SPS: អនាម័យនិងភូតគាមអនាម័យ, TBT: របាំងបច្ចេកទេសលើពាណិជ្ជកម្ម

តារាង៣៖ អត្រាគ្របដណ្តប់ NTM សម្រាប់ការនាំចូលរបស់កម្ពុជា ឆ្នាំ២០១៥

| ផ្នែក HS | ការនាំចូល (លានដុល្លារ) | អត្រាគ្របដណ្តប់ (%) | | | | |
|---|---|---|---|---|---|---|
| | | គ្រប់ប្រភេទ | SPS | TBT | INSP | NTB |
| វាយនភ័ណ្ឌ និងផលិតផល | 4235.6 | 100 | 2.2 | 100.0 | 0.0 | 100 |
| ម៉ាស៊ីន និងបរិក្ខារអគ្គិសនី | 1492.5 | 100 | 0.0 | 100.0 | 0.0 | 100 |
| ផលិតផលរ៉ែ | 1201.1 | 100 | 0.0 | 89.8 | 0.0 | 100 |
| យាន្តយន្ត យន្តហោះ និងនាវា | 1154.7 | 100 | 0.0 | 99.2 | 0.0 | 100 |
| ស្បៀងអាហារបានរៀបចំ ភេសជ្ជៈ ស្រា ទឹកខ្មេះ ថ្នាំជក់ | 731.6 | 100 | 60.2 | 94.7 | 0.0 | 100 |
| លោហៈមូលដ្ឋាន និងផលិតផល | 626.4 | 100 | 0.0 | 0.6 | 0.0 | 100 |
| ផលិតផលឧស្សាហកម្មគីមី និងជាប់ទាក់ទិន | 584.6 | 100 | 0.5 | 84.1 | 4.8 | 100 |
| ជ័រ ប្លាស្ទិក និង ផលិតផល, កៅស៊ូ និងផលិតផល | 572.9 | 100 | 20.3 | 21.2 | 0.0 | 100 |
| ក្រដាស ផ្ទាំងក្រដាសក្រាស់ និងផលិតផល | 328.0 | 100 | 0.0 | 91.2 | 0.5 | 100 |
| ស្បែក និងផលិតផល, គ្រឿងកែបសេះ និងសម្ភារសម្រាប់ធ្វើដំណើរ | 311.6 | 100 | 9.2 | 9.4 | 0.0 | 100 |
| គុជ, ថ្មនិងលោហៈមានតម្លៃ | 261.6 | 100 | 0.0 | 99.9 | 0.2 | 100 |
| ផលិតផលធ្វើពី ថ្ម ម្នាងសិលា សេរ៉ាមិក កែវ | 192.3 | 100 | 0.0 | 0.1 | 0.0 | 100 |
| សត្វរស់ និងផលិតផលសត្វ | 161.9 | 98 | 27.5 | 81.7 | 37.7 | 98 |
| ផលិតផលកម្មន្តសាលផ្សេងៗ | 145.6 | 100 | 0.1 | 1.1 | 0.0 | 100 |
| ស្បែកជើង, មួក, ស្លាបសត្វ, ផ្កាសិប្បនិមិត្ត, ឆ្អិត | 120.8 | 100 | 29.5 | 29.5 | 13.1 | 100 |
| ផលិតផលបន្លែ | 96.1 | 100 | 99.9 | 100.0 | 0.0 | 100 |
| ឧបករណ៍, នាឡិកា, ប្រដាប់ថត និងប្រដាប់ចម្លង | 74.4 | 100 | 3.2 | 38.5 | 0.0 | 100 |
| ឈើ, ស្មោរ និងផលិតផល(ឧ. ឆ្នុកដប), គ្រឿងកន្ត្រកល្អី | 64.2 | 100 | 0.0 | 100 | 99.4 | 100 |
| ខ្លាញ់សត្វបន្លែ, ប្រេង, ក្រមួន | 14.9 | 100 | 16.9 | 100 | 0.0 | 100 |
| ស្នាដៃសិល្បៈ និងវត្ថុបុរាណ | 0.1 | 100 | 64.9 | 100 | 64.9 | 100 |
| អាវុធ និងគ្រាប់រំសេវ | 0.1 | 100 | 75.9 | 100 | 0.0 | 100 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធដោយផ្អែកលើទិន្នន័យរបស់ UN Comtrade (https://comtrade.un.org/) and WITS (https://wits.worldbank.org/)
កំណត់សំគាល់៖ CTPM: វិធានការត្រៀមសម្រាប់ការពារពាណិជ្ជកម្ម, EXP: វិធានការលើការនាំចេញ, INSP: អធិការកិច្ចមុនពេលដឹកជញ្ជូន, QC: ការត្រួតពិនិត្យបរិមាណ, PC: ការត្រួតពិនិត្យថ្លៃ, SPS: អនាម័យនិងភូតគាមអនាម័យ, TBT: របាំងបច្ចេកទេសលើពាណិជ្ជកម្ម

នាំចេញផលិតផលកសិកម្ម ព្រោះលទ្ធផលនៃការសិក្សាបង្ហាញថា កំណើន ១០% ក្នុង NTBs អាចកាត់បន្ថយការនាំចេញផ្នែកកសិកម្មរបស់កម្ពុជាអស់ ២,៧%។

## វិធានការមិនមែនពន្ធគយនៅកម្ពុជា

### *ការវិវត្តវិធានការមិនមែនពន្ធគយ (NTMs)*

ទិន្នន័យទទួលបានបង្ហាញថា កម្ពុជាបានប្រើ NTMs ជាលើកដំបូងនៅឆ្នាំ១៩៨៨ ដោយដាក់អនុវត្ត ៥វិធានការ SPS និង ៤វិធានការ EXP (រូបភាព១)។ មកទល់បច្ចុប្បន្ន កម្ពុជាបានដាក់អនុវត្ត ២៤៣ NTMs លើការនាំចូលមកពី និងការនាំចេញទៅកាន់ គ្រប់ដៃគូពាណិជ្ជកម្មទាំងអស់ គឺមាន ១២១ TBT (៥០% នៃចំនួនសរុប), ៣៦ SPS (១៥%), ១ អធិការកិច្ចមុនពេលដឹកជញ្ជូន (INSP) (០,៤%), ៣ ការត្រួតពិនិត្យគុណភាព (QC) (១%), ១២ ការត្រួតពិនិត្យថ្លៃ (PC) (៥%), និង ៧០ EXP (២៩%) (រូបភាព២ និង តារាង២) ។ ពីឆ្នាំ១៩៨៨ ដល់ ២០១៣ កម្ពុជាបានដាក់អនុវត្តប្រមាណ ១៣ NTMs ជាមធ្យមក្នុងមួយឆ្នាំ។ TBT ជាវិធានការបានប្រើប្រាស់ញឹកញាប់ជាងគេ បន្ទាប់មកគឺ SPS និង EXP។ ក្នុងអំឡុងពេលនោះដែរ កម្ពុជាបានដាក់អនុវត្តជាមធ្យម ៨ TBT, ៥ SPS និង ៤ EXP ក្នុងមួយឆ្នាំ។

### *NTMs កំណត់តាម លេខកូដនៃប្រព័ន្ធសុខដុមនីយកម្ម*

តារាង២ បង្ហាញពី NTMs មានស្រាប់នៅកម្ពុជា កំណត់តាមចំណាត់ថ្នាក់ HS។ ផ្នែក HS ចំនួន ៥ ដែលមាន NTMs ច្រើនជាងគេ គិតតាមលំដាប់ថយចុះ គឺ ១) ផលិតផលឧស្សាហកម្មគីមី និងជាប់ទាក់ទិន ២) ស្បៀងអាហារបានរៀបចំ ភេសជ្ជៈ ទឹកក្រូច ទឹកខ្មេះ និង ថ្នាំជក់ ៣) ផលិតផលបន្លែ ៤) សត្វរស់ និងផលិតផលសត្វ ៥) ខ្លាញ់សត្វនិងបន្លែ ប្រេង និងក្រមួន។ ផលិតផលឧស្សាហកម្មគីមី និងជាប់ទាក់ទិន ជាផ្នែករងឥទ្ធិពលខ្លាំងជាងគេឆ្ងាយណាស់ ដោយមាន ១៥១ NTMs ក្នុងនោះមាន ៨០ TBT, ១៨ SPS, ១ QC, ៦ PC, ៤៥ EXP និង ១ INSP ។ ៤ ផ្នែក HS ដែលរងឥទ្ធិពលខ្លាំងបន្តបន្ទាប់មកទៀតពី NTMs គឺជា ផលិតផលកសិកម្ម។ ផលិតផលទាំងនេះ ច្រើនតែរងឥទ្ធិពលពី SPS ខ្លាំងជាង TBT។ គួរកត់សំគាល់ថា ស្បៀងអាហារបានរៀបចំ ទទួលរងវិធានការ SPS ច្រើនជាងគេ (៣៤) រីឯ ផលិតផលឧស្សាហកម្មគីមី និងជាប់ទាក់ទិន ទទួលរង TBT ច្រើនជាងគេ (៨០)។

### *អត្រាគ្របដណ្តប់ NTM សម្រាប់ការនាំចូលរបស់កម្ពុជា*

តារាង៣ បង្ហាញពីអត្រាគ្របដណ្តប់សម្រាប់ការនាំចូលរបស់កម្ពុជា នៅឆ្នាំ២០១៥។ ផ្នែក HS ភាគច្រើន មានអត្រាគ្របដណ្តប់

រូបភាព៣៖ គម្លាតបទបញ្ញត្តិ NTMs




ប្រភព: ការគណនារបស់អ្នកនិពន្ធដោយផ្អែកលើ WITS (https://wits.worldbank.org/)
កំណត់សំគាល់៖ ការកែខ្នាតច្រើនមុខ (Multidimensional scaling (MDS) (nonmetric), loss criterion = 0.0961)

ខ្ពស់នៃ NTM គ្រប់ប្រភេទ, NTB និង TBT។ ផលិតផល ៤ ដែលនាំចូលច្រើនជាងគេ (វាយនភ័ណ្ឌនិងផលិតផល, ម៉ាស៊ីននិងបរិក្ខារអគ្គិសនី, ផលិតផលរ៉ែ, យានយន្ត យន្តហោះ នាវា) មានអត្រាគ្របដណ្ដប់ SPS ទាបណាស់ ប៉ុន្តែមានអត្រាគ្របដណ្ដប់ TBT ខ្ពស់ជាខ្លាំង។ អត្រាគ្របដណ្ដប់ SPS មានកម្រិតខ្ពស់ខ្លាំងសម្រាប់ផលិតផលកសិកម្មភាគច្រើន រួមទាំង ផលិតផលបន្លែ ស្បៀងអាហារបានរៀបចំ ភេសជ្ជៈ ទឹកក្រូច ទឹកខ្មេះ និង ថ្នាំជក់ និងមានកម្រិតខ្ពស់បង្គួរសម្រាប់ សត្វរស់និងផលិតផលសត្វ ខ្លាញ់សត្វនិងបន្លែ ប្រេង និង ក្រមួន។ អាវុធនិងគ្រាប់រំសេវ និងស្នាដៃសិល្បៈនិងវត្ថុបុរាណ ក៏មានអត្រាគ្របដណ្ដប់ SPS ខ្ពស់ដែរ។

### *គម្លាតបទបញ្ញត្តិនៃ NTMs*

Cadot et al. (2015) បានណែនាំឲ្យប្រើ គម្លាតបទបញ្ញត្តិ ដើម្បីកំណត់ភាពខុសគ្នារវាង របប NTMs ផ្សេងៗនៃប្រទេសខុសៗគ្នា។ ប្រសិនបើប្រទេស ២ ដាក់អនុវត្ត NTMs ដូចគ្នា លើផលិតផលដូចគ្នា គេចាត់ទុកថា ប្រទេសទាំងពីរនេះមានរបប NTMs ដូចគ្នា។ បើសិនមាន NTMs ខុសគ្នាច្រើនកាលណា គម្លាតបទបញ្ញត្តិរវាងរបប NTMs ក៏កាន់តែធំកាលនោះដែរ។ ទិន្នន័យចុះលើរូបភាព៣ បង្ហាញនូវគម្លាតបទបញ្ញត្តិរវាងរបបNTMsរបស់កម្ពុជាជាមួយនឹងសមាជិកអាស៊ានផ្សេងទៀត។ របប NTMs របស់ដៃគូពាណិជ្ជកម្មចម្បងៗផ្សេងទៀត ក៏បានដាក់ចូលដែរ សម្រាប់ធ្វើជាកម្រិតគោល។ ប្រសិនបើប្រទេសពីរនៅជិតគ្នានៅលើក្រាហ្វិក ប្រទេសទាំងនោះមានគម្លាតបទបញ្ញត្តិស្រដៀងគ្នា។ រូបភាពនេះបង្ហាញថា របប NTMs របស់កម្ពុជា នៅជិតប្រទេសសិង្ហបុរី ប៉ុន្តែនៅឆ្ងាយពី ថៃ និង ម៉ាឡេស៊ី ។ របប NTMs របស់កម្ពុជា ខុសប្លែកខ្លាំងពី ប្រទេសវៀតណាមដែលហាក់ដូចជានៅឆ្ងាយពីគេនៅក្នុងអាស៊ាន។ ចំណុចនេះបង្ហាញថា របប NTMs ក្នុងអាស៊ាន មិនសូវដូចគ្នាទេ ដែលអាចរារាំងដល់សមត្ថភាពរបស់រដ្ឋនានាជាសមាជិកអាស៊ានក្នុងការធ្វើសុខដុមនីយកម្មរបប NTMs របស់ខ្លួន។

## ផ្លូវឆ្ពោះទៅមុខ

លទ្ធផលរកឃើញបង្ហាញថា ទិន្នន័យ NTMs សម្រាប់កម្ពុជា នៅក្នុង UNCTAD TRAINS វាមិនថ្មីទាន់ពេលនោះទេ ព្រោះមានត្រឹមឆ្នាំ២០១៣ ។ ទិន្នន័យ NTM ត្រឹមត្រូវ គឺចាំបាច់ណាស់សម្រាប់ឲ្យ ក្រុមហ៊ុនពាណិជ្ជកម្មប្រតិបត្តិតាមបានសម្រេចនូវ NTMs។ តាមនេះ នៅឆ្នាំ២០១៨ សេដ្ឋវិទូនៅវិទ្យាស្ថាន CDRI គ្រោងអនុវត្តគម្រោងស្រាវជ្រាវមួយ ដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យ NTMs នៅកម្ពុជា។ គម្រោងនេះផ្តល់មូលនិធិដោយ ERIA-UNCTAD និងជាចំណែកមួយនៃគម្រោងធំហៅថា ERIA-UNCTAD: ការធ្វើបច្ចុប្បន្នភាព NTMs ក្នុងអាស៊ាន។

លទ្ធផលរកឃើញបានបង្ហាញទៀតថា របប NTMs នៃប្រទេសអាស៊ានមានលក្ខណៈចម្រុះបែប។លក្ខណៈនេះបង្ហាញពីតម្រូវការធ្វើស្តង់ដានីយកម្មរបបNTMsនិង ពន្លឿនដំណើរការរៀបចំឲ្យមានការទទួលស្គាល់ទៅវិញទៅមក ក្នុងតំបន់អាស៊ាន ដើម្បីឲ្យមានលំហូរទំនិញកាន់តែសេរីឡើង។ ថ្វីបើគេដាក់អនុវត្ត NTMs ដើម្បីការពារមនុស្សបរិស្ថាន និងជីវិតសត្វនិងរុក្ខជាតិក្តីប៉ុន្តែNTMs ភាគច្រើនគេប្រើវាជាលេស ដើម្បីការពារផលិតកម្មក្នុងស្រុក។ របាំងមិនមែនពន្ធគយ[2] ទាំងនេះ គួរតែលុបចោល។ ការប្រជុំលើកទី២០ នៃក្រុមប្រឹក្សាតំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA) បានអនុម័តយល់ព្រមលើយន្តការ សម្រាប់ស្វែងរកនិងលុបបំបាត់របាំងមិនមែនពន្ធគយ និងបានកំណត់ថាជា កត្តាសំខាន់បំផុតដើម្បីធ្វើសមាហរណកម្មវិស័យជាអាទិភាពនានា។ រយៈពេលសម្រាប់ការលុបបំបាត់ របាំងមិនមែនពន្ធគយ ប្រែប្រួលខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ។ សម្រាប់ប្រទេស កម្ពុជា មីយ៉ាន់ម៉ា ឡាវ និង វៀតណាម របាំងមិនមែនពន្ធគយ គួរតែកាត់បន្ថយនៅដំណាច់ឆ្នាំ២០១៨។ ទោះយ៉ាងនេះក្តី ការស្វែងរករបាំងមិនមែនពន្ធគយ ក្នុងចំណោម NTMs ដ៏ច្រើនសន្ធឹកសន្ធាប់នោះ មិនមែនជាការងាយស្រួលទេ។ ការស្រាវជ្រាវទៅអនាគតលើ NTMs គួរផ្តោតលើ ការស្វែងរក NTMs ដែលជារបាំងរារាំងពាណិជ្ជកម្ម។ ការធ្វើចំណាត់ថ្នាក់ទៅអនាគតនៃ NTMs គួរមានដាក់បញ្ចូល NTBs ជាប្រភេទមួយដែរ។ ប្រទេសនានាត្រូវរចនារៀបចំយន្តការឲ្យមានប្រសិទ្ធភាព សម្រាប់ស្វែងរក និងផ្ទៀងផ្ទាត់ព័ត៌មានស្តីពី NTBs និងធានាឲ្យមានការលុបបំបាត់វាចោល។

## ឯកសារយោងមាននៅក្នុងទស្សនាវដ្តីជាភាសាអង់គ្លេស

2 របាំងមិនមែនពន្ធគយ ជួនកាលគេប្រើវាដោយខុសឆ្គងទៅជំនួសគ្នាជាមួយនឹងវិធានការមិនមែនពន្ធគយ។ ជាក់ស្តែង វិធានការមិនមែនពន្ធគយ មិនមែនសុទ្ធតែជា របាំងពាណិជ្ជកម្ម នោះទេ។ ក្នុងអត្ថបទនេះ របាំងមិនមែនពន្ធគយ សំដៅដល់ វិធានការមិនមែនពន្ធគយមិនពេញច្បាប់ដែលគេប្រើដើម្បីការពារឧស្សាហកម្ម ឬផលិតផលក្នុងស្រុក។